# សិលាចារឹកប្រាសាទលាក់នាង K.២៦៥

ប្រាសាទលាក់នាង ជាប្រាសាទឥដ្ឋ ប្រាង្គទោល មានទីតាំងនៅជ្រុងឦសាន ប្រាសាទប្រែរូប ចម្ងាយប្រមាណ១២០ម៉ែត្រ ស្ថិតនៅក្នុងឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ប្រាសាទនេះសាងសង់ឡើងក្នុងសតវត្សរ៍ទី១០ ដោយផ្អែកលើផ្តែរប្រាសាទដែលស្ថិតនៅក្នុងរចនាបទប្រែរូប។ នៅប្រាសាទនេះ មានសិលាចារឹកចំនួន២ផ្ទាំង ចារនៅលើមេទ្វារខាងត្បូង និងមេទ្វារខាងជើង ដែលចុះលេខបញ្ជីសារពើភណ្ឌសិលាចារឹកខ្មែរ K.២៦៥។

សិលាចារឹកនេះធ្លាប់សិក្សានិងបោះពុម្ពផ្សាយកន្លងមក ដោយលោកសាស្ត្រាចារ្យ ហ្សក សឺដែស នៅក្នុងសៀវភៅសិលាចារឹកនៃប្រទេសកម្ពុជា ក្បាលទី៤ របស់លោក។[១] បន្ទាប់មក លោកសាស្ត្រាចារ្យ ហ្វីលីព ចេណ្ណឺរ ក៏បានសិក្សានៅក្នុងស្នាដៃរបស់លោក Part xml, № 46 & 48 និងចុះផ្សាយក្នុងគេហទំព័រ http://sealang.net/ok/corpus.htm។[២]

អត្ថបទនៅផ្ទាំងខាងត្បូងបានឱ្យយើងដឹងថានៅមហាសករាជឆ្នាំ៨៨១ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៩៦០ ម្រតាញស្រីរណវីរខ្យាតដែលបានទទួលងារព្រះរាជទានថ្មី(ឈ្មោះនោះដាច់បាត់) និងបានក្រាបទូលព្រះមហាក្សត្រ ដើម្បីទិញដីសន្ទូរ ដែលជារបស់ប្រាសាទព្រះគម្តែងអញស្រីភទ្រេស្វរ(ប្រាសាទបាគង) ព្រះគម្តែងអញភ្នំកណ្តាល(ប្រាសាទភ្នំបាខែង) ព្រះគម្តែងអញបរមេស្វរ(ប្រាសាទព្រះគោ) ពួកអ្នកខ្នាប និងពួកអ្នកអញ្ចោនដើម្បីថ្វាយចំពោះប្រាសាទព្រះគម្តែងអញសិវលិង្គ។ ព្រះមហាក្សត្រចេញបញ្ជាដល់មន្ត្រីឋានៈជាខ្លោញឃ្លាំង និងតម្រួតព្រះរាជការ ឱ្យនាំព្រះបន្ទូលដល់អធិការប្រាសាទ(ខ្លោញវ្នំ) ទេពបរិចារ(អ្នកបម្រើក្នុងប្រាសាទ) ខ្លោញអ្នកបម្រើដែលធ្វើការក្នុងប្រាសាទ និងពួកអ្នកដែលមានដីនៅទីនោះ ប្រើឱ្យថ្វាយដីសន្ទូរទៅប្រាសាទព្រះគម្តែងអញសិវលិង្គ ដែលអ្នកទាំងនោះសុទ្ធសឹងតែធ្វើតាមព្រះរាជបន្ទូល។ ចុងក្រោយជាការរៀបរាប់ពីទ្រព្យធនដែលយកទៅទិញដីនីមួយៗ និងពួកអ្នកដែលបានគោរពតាមព្រះរាជបន្ទូល។

[១] Coedes 1952: 102-105។

[២] សូមជ្រើសយកលេខ K.265S & K.265N។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

ចំណែកឯសិលាចារឹកនៅផ្ទាំងខាងជើង បានខូចខាតអត្ថបទផ្នែកខាងឆ្វេងនិងដាច់បាត់កាលបរិច្ឆេទ។ អត្ថបទនេះបង្ហាញពីមានព្រះរាជបន្ទូលដល់ស្ដេងអញអាចារ្យថ្នាក់ទីពីរ និងកំស្ដេងអញស្រីវីរេន្ទ្រវម្ម៌ ទៅតម្កល់អ្វីម្យ៉ាងឱ្យម្រតាញស្រីវណាបរាក្រមឱ្យដូចមុនវិញ និងរៀបរាប់ពីតង្វាយសម្រាប់ថ្វាយជារៀងរាល់ថ្ងៃនិងសម្រាប់ពិធីដុតស្រូវ។ តង្វាយទាំងអស់មានស្រុក ស្រែ ភូមិករ និងអ្នកបម្រើទាំងនេះ គឺសម្រាប់បម្រើដល់ព្រះ ហើយចៅអធិការប្រាសាទ ខ្លោញការវ៉ារ និងទេពបរិចារ មិនអាចហៅអ្នកបម្រើនេះទៅធ្វើការខាងប្រេងជាដើម នៅប្រាសាទព្រះថ្កោលទេ គឺអ្នកទាំងនោះមាននាទីថ្វាយគ្រឿងវណ្ដាប់បូជាតែប៉ុណ្ណោះ។

ប្រាសាទសិវលិង្គ នៅក្នុងសិលាចារឹកមេទ្វារខាងត្បូងនេះ ហាក់ពុំសំដៅដល់ប្រាសាទលាក់នាងនេះឡើយ គឺទំនងជាសំដៅដល់ប្រាសាទប្រែរូប ជាប្រាសាទរាជ្យរបស់ព្រះបាទស្រីរាជេន្ទ្រវម្ម៌ទេវ ដែលធ្វើពិធីឆ្លងនៅក្នុងគ្រិស្ដសករាជឆ្នាំ៩៦១។ ដីដែលជាវទាំងនោះ គឺជាចំណែកបុណ្យរបស់ម្រតាញស្រីវណាវីខ្យាត ដែលខ្នះខ្នែងជាវដាក់ចំណុះឱ្យប្រាសាទរាជ្យរបស់ព្រះមហាក្សត្រ។ ទំនងជាដោយសារហេតុនោះហើយ ទើបព្រះមហាក្សត្រទ្រង់ប្រទានងារថ្មីមួយដល់ម្រតាញរូបនេះ។ ចំណែកឯប្រាសាទសិវលិង្គនៅជាប់ជើងទំនប់ព្រះតដាក ទើបសំណៅដល់ប្រាសាទលាក់នាងនេះ។ យ៉ាងនេះក្ដី ប្រាសាទនេះច្បាស់ជាស្ថិតនៅក្នុងឧបសម្ព័ន្ធរបស់ប្រាសាទប្រែរូបពុំខាន។

**១- អត្ថបទសិលាចារឹកជាអក្សរខ្មែរទំនើប**

**ផ្ទាំងខាងត្បូង**

១- ៙៨៨១គកបញ្ចមីកេតិផលិ[គុណានុ][[ម្រតាញ៑[៣]]]

២- គ្រីវណាវីខ្យាតតទារិជ្ជះម្រតាញគ្រីន-----

៣- វីរបង្គំថ្ប្វាង្ឋិវេទនបិដៅវនេះភូមិសន្ធូវនៃ[វ្រះក]

៤- ម្រតេងអញ៑គ្រីន្ទ្រីគ្វរនៃវ្រះកម្រតេងអ[ញ៑វ្នុំក]

៥- ន្ដាលិនៃវ្រះកម្រតេងអញ៑បរមេគ្វរនៃវក្ត៌[៤]ខ្នា[[បិនៃវ៑]]

[៣] ជួសយោងតាមសិលាចារឹក K.៣៥២។

[៤] ពាក្យត្រឹមត្រូវជាៈ វត្ត៌។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៦- គ្គ៌អញ្ចេទិបីឱយ្ដវ្រះកម្រតេងអញ្ជិគិរលិង្គ[[មានិ]]

៧- វ្រះគាសនធូលីវ្រះបាទធូលីជេងវ្រះកម្រតេងអ[[ញ្ជិត]]

៨- ម្រតាញ្ជិខ្ញោញ្ជិត្រីវីរេន្ទ្រវម៌្មខ្ញោញ្ជិគ្នាងនាងឯកិ[[ម្រតាញ្ជិ]]

៩- ត្រីនរេន្ទ្របតីខ្ញោញ្ជិគ្នាងនាត្រីណីនុម្រ[[តាញ្ជិ]]

១០- ត្រីន្ទ្របេន្ទ្រវីខ្យាតតំរូចវ្រះរាជកាយ៌្យនាចត្វារិ៎[ប្រេប]

១១- ន្វលិវ្រះគាសនតស្ដេញ្ជិខ្ញោញ្ជិវ្នំនុទេវបរិចារនុ[ខ្ញោ]

១២- ញ្ជិអ្នកិផ្ដោងនាវ្រះហនុវគ្គ៌តមានិភូមិប្រេឱយិ

១៣- ភូមិសន្ធូវតវ្រះកម្រតេងអញ្ជិគិរលិង្គស្យង្គទៅឱយិ[ភូ]

១៤- មិរោះហវ្រះគាសនៈទ្រវ្យមនិជៅវភូមិនាវ្រះ[ក]

១៥- ម្រតេងអញ្ជិត្រីន្ទ្រីគូរក្រេបិ៦ថ្ងៃរិ១០-១គិតទូលិវ្រះ[គាស]

១៦- នស្ដេញ្ជិវម៌្មគិរខ្ញោញ្ជិវ្នំទេវបរិចារសីវិទ្យាមយ [សី]

១៧- កំបិតិខ្ញោញ្ជិអ្នកិសីអគ្គតសីកនិលោញ្ជិសីកនិ--[សី]

១៨- កញ្ចុណោៈភូមិនាវ្រះកម្រតេងអញ្ជិវ្នំកន្ទាលិ[[ក្រេបិ]]

១៩- ៥ថ្ងៃរិ៥តទូលិវ្រះគាសន(ស្ដេញ្ជិខ្ញោញ្ជិវ្នំ)ស្ដេញ្ជិ[ខ្ញោ]

២០- ញ្ជិកាយ៌្យទេវបរិចារសីម្ពូ[[ទុភាវ]](សិកញ្ចុំ)[[ភូមិ]]

២១- នាវ្រះកម្រតេងអញ្ជិបរមេគ្វរ[ក្រេបិ២ថ្ងៃរិ២](តទូលិ)[វ្រះ]

២២- គាសនស្ដេញ្ជិគីវាចាយ៌្យទេវ(បរិចារសិកញ្ញា)ៈនា

២៣- ភូមិវគ្គ៌ខ្នាប្ប(តិទុញ្ជិ)វាបិអំម្ពូត[ខ្ញោញ្ជិផ្ទលិ]ខ្នា(បិ)ថ្ងៃរិ--

២៤- នាភូមិ[[អញ្ចេទិ]]តិទុញ្ជិតតាញ្ជិ--មាសិបា[[ទ]]---

២៥- គុក្តិ១ (បន្ទ្យាកិ)យោ១-----

## ផ្ទាំងខាងជើង

១- --- (គ)កអម្ដមីកេតិអាបាធគុក្រវារនុមានិវ្រះគាសនធូលិវ្រះ

២- [បាទធូ]លីជេងវ្រះកំម្រតេងអញ្ជិតស្ដេងអញ្ជិអាចា

៣- [យ៌្យ](នា)ទោនុកំស្ដេងអញ្ជិត្រីវីរេន្ទ្រវម៌្មបិប្រេតំគល្ងគិ

៤- ---ម្រតាញ្ជិត្រីវណបរាក្រមវងលេងវុតតេលៈ

អត្ថបទដោយៈ ហ៊ុន ឈុនតេង

៥- [វ្រះ]កំម្រតេងអញគិរលិង្គជេងវ្រះតដាកសំសិទ្ធា
៦- [យ]នុវ្រះថ្កូលិកល្បនាស្រុកអំរេកទិកកេះស្រុកអគ្ន
៧- [វា]រ៓ភាជន១កោគ១រង្កោលិះ២ប្រតិទិនវេលាតុតិស្រូ
៨- -ស្រូជេ១ធត្រ១យជ្ជ១ទៅឱយនាតុតិស្រូវគិស្រុ
៩- [កំ]ស្រេកូម្យាករខ្ញុំតសិបំរេតវ្រះ៎យជមាន
១០- (ថ្ងៃ)បូជាវ្រះស្តបិវត្តមានរុតតេលិរ្វំអាចិតិខ្ញោញ
១១- វ្រំនុខ្ញោញកាយ៌្យនុទេវបរិចារហៅអ្នកវ្រះនេះបិប្រេ
១២- តបញ្ជូលផោងនាវ្រះថ្កូលិកល្បនាយជមានគុសិគិត
១៣- ជាបិមានិ៎

## ២- អត្ថបទប្រែសម្រួលជាភាសាខ្មែរទំនើប

### ផ្ទាំងខាងត្បូង

(១-៦) ០មហាសករាជឆ្នាំ៨៨១ ៥កើត ខែផល្គុណ នូវម្រតាញស្រីរណវីរ្យាតដែលទទួលបានឈ្មោះម្រតាញស្រីន-----វីរ ក្រាបបង្គំទូលថ្វាយ(ព្រះមហាក្សត្រ) ដើម្បីជាវដីសន្ទូរនៃព្រះគម្តែងអញស្រីភទ្រេស្វរ(ប្រាសាទបាគង) នៃព្រះគម្តែងអញភ្នំកណ្ដាល(ប្រាសាទភ្នំបាខែង) នៃព្រះគម្តែងអញបរមេស្វរ(ប្រាសាទព្រះគោ) នៃពួកអ្នកខ្ជាប នៃពួកអ្នកអញ្ជេនដើម្បីថ្វាយចំពោះព្រះគម្តែងអញសិវលិង្គ។

(៦-១២) មានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ(ព្រះបាទស្រីរាជេន្ទ្រវម៌្មទេវ) ត្រាស់ដល់ម្រតាញខ្ញោញស្រីរាជេន្ទ្រវម៌្មជាប្រធានឃ្លាំងនាថ្នាក់ទីមួយ ម្រតាញស្រីនរេន្ទ្របតីប្រធានឃ្លាំងនាថ្នាក់ទីបី និងម្រតាញស្រីនឫបេន្ទ្រវីរ្យាតជាតម្រួតព្រះរាជការនាថ្នាក់ទីបួន ប្រើទូលព្រះរាជសាសន៍ឱ្យដល់ស្តេញអធិការប្រាសាទ ទេពបរិចារ និងប្រធានអ្នកបម្រើទាំងឡាយនៅប្រាសាទ និងពួកអ្នកដែលជាម្ចាស់ដី ប្រើថ្វាយដីសន្ទូរចំពោះព្រះគម្តែងអញសិវលិង្គ (អ្នកទាំងនោះ)សឹងថ្វាយដីតាមព្រះរាជសាសន៍។

(១២-១៨) ទ្រព្យដែលយកទៅជាវដីនាព្រះគម្តែងអញស្រីភទ្រេស្វរមាន ក្របី៦ក្បាល គោ១១ក្បាល។ អ្នកទទួលព្រះរាជសាសន៍មានស្តេញវម៌្មសិវៈជាចៅអធិការប្រាសាទ ទេព

[៥] ជួសយោងតាមសិលាចារឹក K.២៦២ និង K.៤៧០។

AMS
អរិយធម៌ខ្មែរ

បរិចារគឺ សីវិទ្យាម័យ (និង)សីកំបិត ប្រធានអ្នកបម្រើគឺសីអ្គត សីកន្ទោញ សីកន-- (និង)សីកញ្ចុណ។

(១៨-២០) ដីនាព្រះគម្តែងអញក្ញុំកណ្ដាល(ទិញនឹង)ក្របី៥ក្បាល គោ៥ក្បាល។ អ្នកទទួលព្រះរាជសាសន៍ គឺស្តេញអធិការប្រាសាទ ស្តេញប្រធានការផារ ទេពបរិចារគឺសីម្រឹទុការ (និង)សីកញ្ចុ។

(២០-២២) ដីនាព្រះគម្តែងអញបរមេសូរ(ទិញនឹង)ក្របី២ក្បាល គោ២ក្បាល។ អ្នកទទួលព្រះរាជសាសន៍គឺស្តេញសិវាចារ្យ ទេពបរិចារគឺសីកញ្ឆា។

(២២-២៣) នាដីពួកអ្នក(នៅតំបន់)ខ្នាបដែលទិញពីវាបអម្រឹតជាខ្ញោញឈ្នួលខ្នាប (ទិញនឹង)គោ--។

(២៤-២៥) នាដីអញ្ចេនដែលទិញពីតាញ--(ទិញនឹង)មាស--បាទ ភាជន៍សុក្តិ១ សម្បៀក ១យៅ -----។

### ផ្ទាំងខាងជើង

(១-៤) មហាសករាជឆ្នាំ--- ៨កើត ខែអាសាឍ ថ្ងៃសុក្រ នូវមានព្រះរាជសាសន៍ធូលីព្រះបាទធូលីជើងព្រះគម្តែងអញ ត្រាស់ដល់ស្តេងអញអាចារ្យនាថ្នាក់ទីពីរ និងកំស្តេងអញស្រីវីរេន្ទ្រវម៌្ម ដើម្បីប្រើតម្កល់គឺ--- ម្រតាញស្រីរណបរាក្រមឡើងវិញឱ្យដូច(ដើម)ដដែល។

(៥-៨) ព្រះគម្តែងអញសិវលិង្គនៅជាប់ព្រះតដាក ចូលរួមសិទ្ធិជាមួយ(ប្រាសាទ)ព្រះថ្កោល។ រៀបចំរណ្ដាប់បូជា(ថ្វាយ)ស្រុកអំរែកទឹកកេះ (និង)ស្រុកអស្វរារ (មាន)ភាជន៍១ លិង្គកោស(គម្របលិង្គ)១ អង្ករ២លិះ រៀងរាល់ថ្ងៃ។ (សម្រាប់)វេលាដុតស្រូវ- (ថ្វាយ)ស្រូវ១ដើ ធត្រ១ យជ្ញ១ (យក)ទៅថ្វាយនាកន្ទែងដុតស្រូវ។

(៨-១០) ស្រុក ស្រែ ភូមិករ អ្នកបម្រើទាំងអស់ គឺ(ដើម្បី)បម្រើព្រះ។ អ្នកធ្វើពិធីបូជាធ្វើពិធីបូជាព្រះនិងស្តាប់ព័ត៌មានដូច(ដើម)ដដែល។

(១០-១៣) ពុំអាចមានខ្ញោញក្ញុំ ខ្ញោញការផារ និងទេពបរិចារ (មក)ហៅ(យក)អ្នកបម្រើព្រះទាំងនេះ ដើម្បីប្រើឱ្យទៅធ្វើការខាងប្រេងផងនាព្រះថ្កោលឡើយ គឺ(អ្នកបម្រើទាំងនេះ) ធ្វើតែជាអ្នកថ្វាយគ្រឿងរណ្ដាប់បូជាមួយ(មុខ)គត់។

អត្ថបទដោយៈ ហ៊ុន ឈុនតេង

## ៣- សរុប

យោងតាមអត្ថបទសិលាចារឹកទាំងពីរនេះ គឺពុំបានបង្ហាញឱ្យយើងដឹងអំពីការកសាងប្រាសាទនេះឡើយ ប៉ុន្តែបានបង្ហាញអំពីការដារដីសម្រាប់ថ្វាយប្រាសាទ របៀបនៃការដារដី ព្រមទាំងការកំណត់ចាត់ចែងប្រាសាទឱ្យដាក់រួមគ្នា ការកំណត់គ្រឿងរណ្តាប់បូជា និងការកំណត់តួនាទីរបស់អ្នកបម្រើជាដើម។

អ្វីដែលគួរឱ្យចាប់អារម្មណ៍បន្ថែមទៀតនោះ គឺពាក្យ «[វ្រះ]កំម្រតេងអញ៑គិរលិង្គ ជេង៑វ្រះតដាក» ដែលមានន័យថា «ប្រាសាទសិវលិង្គនៅជើង(ទំនប់)ព្រះតដាក»។ ចំពោះពាក្យ «វ្រះតដាក» ឬ «ព្រះតដាក» នេះហើយ ដែលវិវត្តមកជា «ប្រដាក» ឬ «ព្រះដាក់» នាពេលបច្ចុប្បន្ន។ ថ្វីដ្បិតតែមានរឿងព្រេងនានា ពន្យល់អំពីស្ថាននាមឃុំព្រះដាក់នេះក្តី កស្តុតាងសិលាចារឹកនេះ មានតម្លៃដែលអាចឱ្យយើងជឿជាក់និងប្រើប្រាស់បាន។[6]

ម្យ៉ាងទៀត ពាក្យ «តុតិស្រូ» សំដៅដល់ដល់កិច្ចពិធីដុតស្រូវ ក៏អាចបង្ហាញឱ្យយើងឃើញពីទំនៀមទម្លាប់មួយបែប ដែលបន្សល់ស្លាកស្នាមជាទួលអង្ករខ្មៅ នៅតាមទីតាំងមួយចំនួនក្នុងប្រទេសកម្ពុជា ដូចជាទួលអង្ករខ្មៅនៅស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង និងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យជាដើម។ សម្រាប់ចំណុចនេះ មានអត្ថបទរបស់ AMS អរិយធម៌ខ្មែរធ្លាប់ផ្សព្វផ្សាយរួចមកហើយ សូមអានបន្ថែមតាមរយៈ៖ https://ams.com.kh/khmercivilization/detail/4869។

## ឯកសារពិគ្រោះ

Cœdès, G.

1952. Inscription de Pràsàt Lằk Nằṅ (K. 265) in *Inscriptions du Cambodge*, Vol. 4. Paris.

[6] សូមអានបន្ថែម៖ https://bit.ly/3BBN4ZW។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

## បញ្ជីរូបភាព



ប្រាសាទលោក់នាង (រូបថត៖ ហ៊ុន ឈុនតេង)



ប្រាសាទលោក់នាង (រូបថត៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង





ទ្វារប្រាសាទ និងសិលាចារឹកមេទ្វារខាងត្បូង (រូបថត៖ ហ៊ុន ឈុនតេង)



សិលាចារឹកមេទ្វារខាងជើង (រូបថត៖ ហ៊ុន ឈុនតេង)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកមេទ្វារខាងត្បូង (រូបថត៖EFEO_CAM17018-1)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



សំណៅផ្តិតសិលាចារឹកមេទ្វារខាងត្បូង (រូបថត៖EFEO_CAM17018-2)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង